**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៧១២ ប្រក.កសក

# ប្រកាស

## ស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

-យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** កំណត់នូវការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់សម្រាប់មន្ត្រីត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ ។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

**ប្រការ ២** : ឯកសណ្ឋាន និង សញ្ញាសម្គាល់នេះសម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ចូលរួមសវនាការនៅតុលាការ និង ក្នុងពិធីផ្លូវការផ្សេងៗទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** : ឯកសណ្ឋានសម្រាប់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វត្រូវកំណត់យកសាច់ក្រណាត់តេហ្គាលឡែន ពណ៌កាគីសាច់ឈើ និង បែងចែកតាមតួនាទីដូចខាងក្រោម :

១-ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យនៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង ប្រធាន អនុប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុង ។

២-មន្ត្រីបច្ចេកទេសជំនាញ ។

**ប្រការ ៤** : ឯកសណ្ឋានរបស់ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និង ប្រធាន អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត ក្រុង សម្រាប់បំពេញបេសកកម្មក្នុងប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ចូលរួមសវនាការនៅតុលាការ និង ពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាងក្រោម :

**ក-ចំពោះបុរស**

១-អាវដៃខ្លី កបើក ប៉ូលស្កា នៃកខ្នង មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្ដាល គម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្ដាល គម្របរាងចតុកោណកែង ឡេវមានត្រារូបព្រះសង្ហារពណ៌មាស ។

២-ខោជើងវែងដេរអំពីសាច់ក្រណាត់ និង ពណ៌ដូចអាវ ចង្កេះដេរតថ្នេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និង ហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ ។

៣-ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

៤-ខ្សែក្រវាត់ ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាស ។

**ខ-ចំពោះស្ត្រី**

១-អាវម៉ូតដូចបុរសដែរ ។

២-ខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ ឬ សំពត់ហ្សីបសាច់ក្រណាត់ និង ពណ៌ដូចអាវ កាត់ស្រុងក្រោមជង្គង់ នៃកក្រោយ រូតចំហៀង ។

៣-ស្បែកជើងឃ្លុប កខ្លី មានកែង ស្បែកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

៤-ខ្សែក្រវ៉ាត់ ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។

**ប្រការ ៥** : ឯកសណ្ឋានរបស់មន្ត្រីជំនាញសម្រាប់ត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ចូលរួមសវនាការនៅតុលាការ និង ពិធីផ្លូវការផ្សេងៗត្រូវកំណត់ដូចខាងក្រោម :

**ក_ចំពោះបុរស**

១-អាវដៃខ្លី ឬ ដៃវែង កឌុប ចោះឡេវចុងក ប៉ូលស្មា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាលគម្របរាង ស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ ។

២-ខោ ស្បែកជើង ខ្សែក្រវ៉ាត់ ដូចគ្នាក្នុងប្រការ៤ ចំណុចក២ ចំណុចក៣ និង ចំណុចក៤នៃប្រកាសនេះ ។

**ខ_ចំពោះស្ត្រី**

១-អាវដៃខ្លី ឬ ដៃវែង កឌុប ចោះឡេវចុងក ប៉ូលស្មា ហោប៉ៅពីរដេរបត់ផ្នត់កណ្ដាលគម្របរាង ស្លឹកពោធិ៍ជីបចង្កេះ ។

២-ខោ និង សំពត់ហ្សីប ស្បែកជើង ខ្សែក្រវ៉ាត់ ដូចគ្នាក្នុងប្រការ៤ ចំណុចខ២ ចំណុចខ៣ និង ចំណុចខ៤ នៃប្រកាសនេះ ។

**ប្រការ ៦** : អំពីមួករបស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ សម្រាប់ប្រើប្រាស់ ក្នុងពេលប្រតិបត្តិការត្រូវកំណត់ដូចខាងក្រោម :

មួកកាស្កេតមានសាច់ក្រណាត់ និង ពណ៌ដូចខោ-អាវ ក្បាំងពណ៌ខ្មៅ និង មានកណ្ដាប់វិណ្ឌប៉ាន ពណ៌ទឹកប៊ិក ផ្នែកខាងលើកណ្ដាប់វិណ្ឌមានភ្ជាប់ត្រារូបព្រះសង្ការពណ៌មាស កម្ពស់៧៨មីល្លីម៉ែត្រ ទទឹង ៦៨មិល្លីម៉ែត្រ។ ផ្នែកខាងមុខក្រោមកណ្ដាប់វិណ្ឌមានកម្រងខ្សែសយពណ៌មាសចុងខ្សែទាំងសងខាងភ្ជាប់ ឡេវត្រារូបព្រះសង្ការមួយពណ៌មាស ។

**មួកកាស្កេតមានបួនប្រភេទគឺ :**

**ចំពោះប្រធាន អនុប្រធាននាយកដ្ឋាន :** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំ កណ្ដាលនិងអមដោយក្បាច់ស្លឹកភ្ញីទេសប្រាំមួយទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក។ នៅលើកណ្ដាប់វិណ្ឌផ្នែកខាងមុខចំកណ្ដាលរចនាដោយបាច់ផ្កាភ្ញីទេស និង អមដោយក្បាច់ស្លឹកភ្ញីទេស ពណ៌មាសទំហំទទឹង២០មិល្លីម៉ែត្រ ។

**ចំពោះថ្នាក់ការិយាល័យ :** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្ដាល និង អ ម ដោយក្បាច់ស្លឹកភ្ញីទេសបួនទងពណ៌មាសទម្រង់ស្នែងក្របី ចុងសងខាងចន្លោះពីជើងមួក២០មិល្លីម៉ែត្រ។

**ចំពោះប្រធានស្នាក់ការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ :** លើជាយក្បាំង

ពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និង អមដោយក្បាច់សន្លឹកភ្ញីទេសពីរទងពណ៌មាស ទម្រង់ស្លែងក្របី ចុងសងខាងចន្លោះពីជើងមួក៤០មិល្លីម៉ែត្រ ។

**ចំពោះមន្ត្រីជំនាញត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ** : លើជាយក្បាំងពណ៌ខ្មៅមានវិណ្ឌទំហំ០៥មិល្លីម៉ែត្រ ពណ៌មាសព័ទ្ធវង់ដល់ជើងមួក ។

**ប្រការ ៧ : ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ :** ធ្វើពីលោហធាតុដែលមានរាងមូលមានអង្កត់ផ្ចិត២៧មិល្លីម៉ែត្រ ផ្ទៃខាងក្នុងមានកួរស្រូវរាងជារង្វង់ស្លែងក្របី នៅខាងក្រោមមានសរសេរអក្សរថា " **បសុពេទ្យ** "ពណ៌ខៀវ លើអក្សរបសុពេទ្យមានអក្សរវេធំ " V " ហើយចំកណ្តាលមានរូបពស់រុំព័ទ្ធម្ជុល និង នៅលើរូបពស់មានរូបប្រាសាទកំពូលបី ។

**ស្លាកសញ្ញាសម្គាល់នេះចែកជាបីប្រភេទគឺ :**

១-ពណ៌មាសសម្រាប់ថ្នាក់ការិយាល័យ និង ថ្នាក់នាយកដ្ឋាន ។

២-ពណ៌ប្រាក់សម្រាប់ប្រធានស្នាក់ការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ ។

៣-ពណ៌សំរិទ្ធិសម្រាប់មន្ត្រីបច្ចេកទេសជំនាញត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ។

**ប្រការ ៨ : ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើតម្រាបហោប៉ៅអាវស្តាំ :** ធ្វើអំពីជ័ររឹង មានផ្ទៃពណ៌ទឹកប៊ិកដែលមានទំហំទទឹង២០មិល្លីម៉ែត្រ បណ្តោយ១០០មិល្លីម៉ែត្រកម្រាស់០២មិល្លីម៉ែត្រ នៅចំហៀងខាងឆ្វេងសញ្ញាសម្គាល់ឈ្មោះ មានសញ្ញាសម្គាល់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទំហំ១៧មិល្លីម៉ែត្រ និង ១៥មិល្លីម៉ែត្រខណ្ឌដោយបន្ទាត់ពណ៌ស នៅចំហៀងខាងស្តាំខណ្ឌដោយបន្ទាត់ពណ៌សចំពាក់កណ្តាលស្របបណ្តោយផ្នែកខាងលើឈ្មោះមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វសរសេរជាអក្សរខ្មែរ និង ផ្នែកខាងក្រោមសរសេរជាអក្សរឡាតាំងពណ៌មាស ។

**ប្រការ ៩ : ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែរតម្រាបហោប៉ៅអាវស្តាំ** : មានរាងមូលប៉ោងធ្វើពីលោហធាតុមានអង្កត់ផ្ចិត៤៧មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែកពណ៌ឈាមជ្រូក ត្រូវបានកំណត់ដូចខាងក្រោម :

**-ផ្នែកខាងលើ :** មានប្រាសាទកំពូលបី

**-ផ្នែកខាងក្រោម អក្សរកាត់ "ន.ផ.ប" :** ជានិមិត្តរូប នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

**-ផ្នែកសងខាង :** មានកួរស្រូវ រាងជារង្វង់ស្លែងក្របីពណ៌មាស

**-ផ្នែកចំកណ្តាលសញ្ញាសម្គាល់មាន :**

•រូបមែកឈើមានស្លឹកបី ជានិមិត្តរូបដំណាំចំណីសត្វ

•រូបសត្វទាំងប្រាំបួនស្ថិតក្នុងផ្ទៃពណ៌បៃតង ពណ៌ផ្ទៃមេឃ ជានិមិត្តរូបផលិតកម្មសត្វវាលស្មៅ ចិញ្ចឹមសត្វ និង សក្តានុពលនៃអភិវឌ្ឍន៍ការចិញ្ចឹមសត្វ

•ផ្ទាំងពណ៌ទឹកប៊ិកបីជ្រុង ជានិមិត្តរូបចំណងទាក់ទងរវាងសត្វ ភ្នាក់ងារចម្លងជំងឺ និង បរិស្ថាន

•អក្សរវេធំ " V " ពណ៌មាស ជានិមិត្តរូបបសុពេទ្យ

•រូបពស់ពណ៌មាស ជានិមិត្តរូបបសុឱសថ

•ម្ជុលពណ៌មាសដែលពស់រុំព័ទ្ធ ជានិមិត្តរូបការការពារ និង ព្យាបាលសត្វ

•ផ្ទៃពណ៌ទឹកមាសនៅក្នុងរង្វង់មូលដែលព័ទ្ធជុំវិញផ្ទៃពណ៌ទឹកប៊ិក ជានិមិត្តរូបចំណូលគ្រួសារ និង សេដ្ឋកិច្ចជាតិ ។

**ប្រការ ១០ : ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ :** ធ្វើពីក្រណាត់ដែលមានរាងមូល ម្ចាន អង្កត់ផ្ចិត៧០មិល្លីម៉ែត្រ ប៉ាក់នឹងអំបោះសូត្រ ត្រូវបានកំណត់ដូចខាងក្រោម :

-**ផ្ទៃខាងលើមានពណ៌ទឹកប៊ិក :** មានអក្សរ "**បសុពេទ្យ**" ពណ៌ស

-**ផ្នែកខាងក្រោមមានពណ៌បៃតងខ្ចី :** មានអក្សរ " VETERINARY " ពណ៌ស

-**ផ្នែកចំកណ្តាលស្លាកសញ្ញាមានរាងបីជ្រុង :** មានផ្ទៃពណ៌ទឹកប៊ិក អក្សរវេធំ "V" និង ពស់រុំព័ទ្ធម្ជុល ពណ៌មាស ព័ទ្ធជុំវិញផ្ទៃពណ៌ទឹកប៊ិកមានពណ៌មាស ។

**ប្រការ ១១ :** របបកំណត់សិទ្ធិប្រើប្រាស់ឯកសណ្ឋាន និង សញ្ញាសម្គាល់ ត្រូវបានផ្តល់ដល់មន្ត្រីម្នាក់ៗដូចបាន កំណត់ក្នុងប្រកាសនេះចំនួនពីរ(២)សម្រាប់ សម្រាប់ប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំម្តង ។

**ប្រការ ១២ :** ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រង ចែកចាយ ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋាន និង សញ្ញាសម្គាល់ ដូចមានកំណត់ក្នុងប្រកាសនេះ ។

**ប្រការ ១៣ :** ក្នុងពេលបំពេញបេសកកម្មមន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វត្រូវ ស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និង មានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

**ប្រការ ១៤ :** ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១៥ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រកាសនេះមានអានុភាពអនុវត្តរហូតដល់មានអនុក្រឹត្យស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ មកជំនួស ។

**ប្រការ ១៦ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ ស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្មនិងបសុពេទ្យាបាល និង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០០៤

**រដ្ឋមន្ត្រី**

ឈឹម-សារុន

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត ក្រុង

-ដូចប្រការ១៦

-ឯកសារ-កាលប្បវត្តិ

## គំរូឯកសណ្ឋាន និងសញ្ញាសំគាល់របស់មន្ត្រីត្រួតពិនិត្យអនាម័យសត្វនិងផលគផលមានដើមកំណើតពីសត្វ

### មួកកាស្កេត


១. ថ្នាក់នាយកដ្ឋាន


២.ថ្នាក់ការិយាល័យ


៣.ប្រធានស្នាក់ការ


៤.មន្ត្រីបច្ចេកទេស

### ស្លាកសញ្ញាសម្គាល់ពាក់លើចុងកអាវឆ្វេងស្តាំ


១.មន្ត្រីបច្ចេកទេស សំរិទ្ធ


២.ប្រធានស្នាក់ការ ពណ៌ប្រាក់


៣.ថ្នាក់ការិយាល័យ-នាយកដ្ឋាន ពណ៌មាស



ស្លាកសញ្ញាសំគាល់ឈ្មោះសម្រាប់ពាក់លើគំរបហោប៉ៅអាវស្តាំ


ស្លាកសញ្ញាសំគាល់សម្រាប់ព្យួរលើគម្របហោប៉ៅអាវស្តាំ



ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដៃអាវស្តាំ